ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការកែតំរូវ

# កិច្ចព្រមព្រៀង

រវាង

## មជ្ឈមណ្ឌលជាតិ

## ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

និង

## បណ្តាញអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍កម្ពុជា

ស្តីអំពី

**កិច្ចសហការផ្តល់ការគាំទ្រសកម្មភាពមណ្ឌលមិត្តជួយមិត្ត**

ឆ្នាំ ២០០៧ ~ ២០០៨

## I. សេចក្តីផ្តើម

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) នៃក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៅកម្ពុជា (CPN+) បាន យល់ព្រមសហការគ្នា ដើម្បីអនុវត្តការងារផ្តល់ការគាំទ្រដល់មណ្ឌលមិត្តជួយមិត្ត (MMM) មួយចំនួន។

CPN+ គឺជាបណ្តាញអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍នៅកម្ពុជា ដែលទទួលស្គាល់ជាផ្លូវការ ដោយ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជានៅខែកក្កដា ឆ្នាំ២០០១ ។ CPN+ បានទទួលថវិកាពីមូលនិធិសកល ជុំទី៤ ដើម្បីរៀបចំ និងអនុវត្តសកម្មភាពមណ្ឌលមិត្តជួយមិត្ត (MMM) នៅតាមមន្ទីរពេទ្យបង្អែកនៃស្រុកប្រតិបត្តិ មួយចំនួន ដែលជាការគាំទ្រផ្លូវកាយ ផ្លូវចិត្ត ផ្លូវសង្គម និងផ្លូវច្បាប់ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង CPN+ នឹងសហការជាមួយមន្ទីរ សុខាភិបាលខេត្ត-ក្រុង ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជាដៃគូដើម្បី អនុវត្តសកម្មភាពមណ្ឌលមិត្តជួយមិត្ត ទៅតាមនិយាមនៃបែបបទ ស្តីពីការអនុវត្តន៍សកម្មភាពមណ្ឌលមិត្តជួយមិត្ត (MMM) ដែលអនុម័តដោយក្រសួងសុខាភិបាល។

គោលបំណង សកម្មភាព និងទីកន្លែងអនុវត្តការងារនៃមណ្ឌលមិត្តជួយមិត្តដែលគាំទ្រដោយបណ្តាញ អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៅកម្ពុជា នៅក្នុងកិច្ចព្រមព្រៀងនេះ មានដូចខាងក្រោមៈ

## II. គោលបំណង

១. ពង្រឹងសកម្មភាពមណ្ឌលមិត្តជួយមិត្ត (MMM) ក្នុងការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គម និងសុខភាព ដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។
២. បង្កើនការចូលរួមរបស់អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ក្នុងសកម្មភាពថែទាំ និងព្យាបាល បន្ត ។
៣. លើកកំពស់ការទទួលបានការថែទាំព្យាបាលអ្នកជំងឺអេដស៍ រួមទាំងការព្យាបាលដោយ ARV ។
៤. លើកកំពស់ការព្យាបាលអោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ (adherence to treatment) របស់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ។

## III. សកម្មភាព និង ការទទួលខុសត្រូវ

### ក. សកម្មភាព និងការទទួលខុសត្រូវ របស់បណ្តាញអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍កម្ពុជា

- រៀបចំអោយមានការប្រជុំប្រចាំខែ របស់មណ្ឌលមិត្តជួយមិត្ត (MMM) ដែលមានអ្នកផ្ទុកមេរោគ អេដស៍ចូលរួមយ៉ាងតិចចាប់ពី ១០០ នាក់ ដល់ ១៥០ នាក់។
- ជ្រើសរើសអ្នកសំរបសំរួល និងជំនួយការមណ្ឌលមិត្តជួយមិត្ត (MMM) ក្នុងស្រុកប្រតិបត្តិ ដែលឧបត្ថម្ភ ដោយ CPN+ ***(ដូចមានរាយឈ្មោះជូនភ្ជាប់ក្នុងតារាងទី "១")*** ជាអ្នកសំរបសំរួល និង ជំនួយការបណ្តាញ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នៅ ស្រុកប្រតិបត្តិ (DPN+) ។
- បន្តការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់មណ្ឌលមិត្តជួយមិត្ត (MMM) តាមរយៈបណ្តាញនៃ អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ថ្នាក់ស្រុកប្រតិបត្តិ (DPN+) ដែលឧបត្ថម្ភដោយបណ្តាញ អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ប្រចាំកម្ពុជា ***(ដូចមានរាយឈ្មោះជូនភ្ជាប់ក្នុងតារាងទី "១")*** ។

- រៀបចំកិច្ចប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំសំរាប់ថ្នាក់ជាតិ និងអន្តរជាតិ ។
- សហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋាភិបាល ក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។
- ស្វែងរកជំនួយថវិកាដើម្បីធានានិរន្តភាពរបស់បណ្តាញ និងមណ្ឌលមិត្តជួយមិត្ត (MMM) សំរាប់ជួយដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ប្រចាំកម្ពុជា ។
- ពង្រឹងសមត្ថភាព និងកសាងជំនាញដល់អ្នកសំរបសំរួលមណ្ឌលមិត្តជួយមិត្ត (MMM) ។
- ពង្រឹងទំនាក់ទំនង និងចែករំលែកពតិមានរវាងមណ្ឌលមិត្តជួយមិត្ត (MMM) ទូទាំងប្រទេស ។
- ធ្វើការស្វែងរកការគាំទ្រស្តីពីតម្រូវការ និងសិទ្ធិរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។
- តាមដាន និងវាយតំលៃគំរោងកម្មវិធី និងផ្តល់ឱ្យម្ចាស់ជំនួយ ។
- បញ្ចូលសកម្មភាព និងថវិការបស់មណ្ឌលមិត្តជួយមិត្ត (MMM) ទៅក្នុងផែនការសកម្មភាព និងរបាយការណ៏ប្រចាំឆ្នាំ និងត្រីមាសរបស់កម្មវិធីអេដស៏ខេត្ត-ក្រុង ។
- ផ្តល់ការគាំទ្រ និងជួយតាមដានការព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដើម្បីឱ្យអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៏ គោរពតាមការព្យាបាលបានត្រឹមត្រូវ និងជាប់លាប់ ។

**ខ. សកម្មភាព និងការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

- សំរបសំរួលជាមួយមន្ទីរសុខាភិបាលខេត្ត ដើម្បីផ្តល់កន្លែងនៅក្នុងមណ្ឌលមិត្តជួយមិត្ត (MMM) ជាទីតាំងការិយាល័យរបស់បណ្តាញអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ (DPN+) ចំពោះ ខេត្ត-ក្រុងដែលមានកម្មវិធីថែទាំបន្ត និងមានអគារមណ្ឌលមិត្តជួយមិត្ត (MMM) ។
- សហការជាមួយមន្ទីរសុខាភិបាលខេត្ត និង CPN+ ក្នុងការជ្រើសរើសអ្នកសំរបសំរួល និងជំនួយការសំរបសំរួលមណ្ឌលមិត្តជួយមិត្ត (MMM) ។
- គាំទ្រយ៉ាងសកម្មដល់សកម្មភាពនៃបណ្តាញអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៏តាមបណ្តាខេត្ត និងស្រុកប្រតិបត្តិ ។
- ផ្តួចផ្តើមបង្កើត និងគាំទ្រសកម្មភាពក្រុមមិត្តគាំទ្រមិត្ត របស់អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៏ ។
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកាទៅតាមលទ្ធភាពដល់ CPN+ ដើម្បីអនុវត្តសកម្មភាពមណ្ឌលមិត្តជួយមិត្ត (MMM) ។

## IV. ទីកន្លែងអនុវត្តគំរោងមណ្ឌលមិត្តជួយមិត្ត

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ប្រគល់អោយបណ្តាញអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍នៅកម្ពុជា (CPN+) បន្តការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់មណ្ឌលមិត្តជួយមិត្ត ចំនួន ១៤ កន្លែង ***(ដូចមានក្នុងកិច្ចព្រមព្រៀងរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើស្បែកនិងកាមរោគ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំកម្ពុជា ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៧)*** និង មណ្ឌលមិត្តជួយមិត្តចំនួន

០៦ កន្លែងបន្ថែមទៀតគឺ ១.ស្រុកប្រត្តិបត្តិ តាខ្មៅ ខេត្តកណ្តាល ២.ទីរូមខេត្តកំពត ៣.ទីរូមខេត្តសៀមរាប ៤.ទីរូមខេត្តកំពង់ឆ្នាំង ៥.ស្រុកប្រតិបត្តិ គីរីវង្ស ខេត្តតាកែវ និង ៦.ស្រុកប្រតិបត្តិ អង្គរកា ខេត្តតាកែវ ។

## V. ប្រភពថវិកា

បណ្តាញអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ បានទទួលថវិកាពីមូលនិធិសកលជុំទី ៤ ដើម្បីអនុវត្តសកម្មភាព មណ្ឌលមិត្តជួយមិត្ត (MMM) និងគាំទ្រការថែទាំបន្ត CoC នេះ ។

## VI. ថេរវេលា

- ចំពោះមណ្ឌលមិត្តជួយមិត្ត ដែលបានឯកភាពក្នុងកិច្ចព្រមព្រៀងរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើស្បែកនិងកាមរោគ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំកម្ពុជា ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៧ នៅតែមានសុពលភាពដដែល ។
- ចំពោះមណ្ឌលមិត្តជួយមិត្ត ៦ កន្លែងបន្ថែមទៀត គឺចាប់អនុវត្តសកម្មភាពចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៨ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨។

## VII. លក្ខខណ្ឌផ្សេងៗ

បណ្តាញអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នឹងរៀបចំផែនការសកម្មភាពរបស់ខ្លួនសំរាប់ឆ្នាំ ២០០៧-២០០៨ និងបញ្ចូលផែនការសកម្មភាពនេះ ទៅក្នុងផែនការសកម្មភាពគ្រប់ជ្រុងជ្រោយប្រចាំឆ្នាំរបស់កម្មវិធីអេដស៍ ខេត្ត-ក្រុង ពាក់ព័ន្ធ។ ការផ្លាស់ប្តូរសកម្មភាពណាមួយនៃផែនការសកម្មភាពដែលបានឯកភាពគ្នារួចហើយ អាចធ្វើឡើងបានដោយ មានការពិគ្រោះយោបល់ និងមានការឯកភាពពីមន្ទីរសុខាភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគ ។

ការសំរបសំរួល ការធ្វើផែនការ និងការគ្រប់គ្រងសកម្មភាពទាំងអស់ខាងលើ នឹងអនុវត្តដោយបណ្តាញ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍កម្ពុជា ដោយសហការពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយគោរពទៅតាមគំរោងផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៤-២០០៧ របស់ក្រសួងសុខាភិបាល ។

| | |
|---|---|
| ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៥ ខែ ០៧ ឆ្នាំ ២០០៧ | ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៥ ខែ ០៧ ឆ្នាំ ២០០៧ |
| ឯ.ឧ. វេជ្ជ. មាន ឈីវុន | ហេង សុខរិទ្ធិ |
| ប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | អ្នកសំរបសំរួល បណ្តាញនៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍កម្ពុជា |

**ចំលងជូន :**

- NCHADS AIDS Care Unit

Table 1:

**LIST MMM SITES**

| No | PROVINCES | # of OD | OD NAME | SUPPORTED BY |
|---|---|---|---|---|
| 1 | Kandal | 2 | Koh Thom - OD | CPN+ |
| | | | Ta Khmao - OD | CPN+ |
| 2 | Kampot | 2 | Kampong Trach - OD | CPN+ |
| | | | Kampot - OD | CPN+ |
| 3 | Prey Veng | 3 | Prey Veng - OD | CPN+ |
| | | | Neak Leuong - OD | CPN+ |
| | | | Pea Reang - OD | CPN+ |
| 4 | Svay Rieng | 2 | Svay Rieng - OD | CPN+ |
| | | | Romeas Hek - OD | CPN+ |
| 5 | Kampong Thom | 1 | Kampong Thom - OD | CPN+ |
| 6 | Siem Reap | 2 | Siem Reap - OD | CPN+ |
| | | | Soth Nikum - OD | CPN+ |
| 7 | Kampong Speu | 1 | Kampong Speu - OD | CPN+ |
| 8 | Kampong Chhnang | 1 | Kampong Chhnang - OD | CPN+ |
| 9 | Takeo | 3 | Done Keo - OD | CPN+ |
| | | | Kirivong - OD | CPN+ |
| | | | Angroka - OD | CPN+ |
| 10 | Banteay Meanchey | 1 | Serey Sophorn - OD | CPN+ |
| 11 | Oddor Meanchey | 1 | Oddor Meanchey - OD | CPN+ |
| 12 | Stung Treng | 1 | Stung Treng - OD | CPN+ |
| **TOTAL** | | **20** | | |

05/09/07

Approved

Prepared by CPN+ Secretariat

Cambodian People Living With HIV/AIDS Network CPN+

Heng. Sok Rithy